**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង អប់រំ យុវជន និង កីឡា**
**លេខ :** ៤៥៩ **អយក** .ប.ក

# ប្រកាស
# ស្តីពី
# តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

* * * * * * * * *

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ .៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស.រកម.០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញ អនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការប្រែក្លាយមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## ស ម្រ េ ច

**ប្រការ ១** : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អក្សរកាត់ **ស.ភ.ន.វ.ស** មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តក្នុងជីវភាពសង្គម ។

**ប្រការ ២** : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចមានភារកិច្ចដូចតទៅ ÷

-បណ្តុះបណ្តាលធនធានមនុស្សថ្នាក់មធ្យម និងថ្នាក់ឧត្តមសម្រាប់ផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច ផ្នែកគណនេយ្យ ផ្នែកហិរញ្ញវត្ថុ-ធនាគារ និងផ្នែករដ្ឋបាលសាធារណៈតាមស្តង់ដាជាតិ និងអន្តរជាតិនិងធ្វើឱ្យកើតការអ្នកទាំងនោះដោយបង្កើន ទាំងបរិមាណ និងគុណភាព ស្របតាមតម្រូវទីផ្សារ ពលកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមទាំងក្នុងប្រទេស និងក្រៅប្រទេស : បណ្តុះបណ្តាលតាមប្រព័ន្ធសាកលវិទ្យាល័យ តាមរយៈការអប់រំ ការបង្រៀន ការរៀន ព្រមទាំងការបណ្តុះបណ្តាលបន្ត ដែលផ្តល់ឯកទេសជំនាញ ប្រកបដោយគុណភាព ការរៀបចំសិក្ខាសាលា និងសន្និសីទផ្សេងៗ ។ល។

-បង្កើនសមត្ថភាព ជំនាញដល់គ្រូបង្រៀន សាស្ត្រាចារ្យ និង មន្ត្រីរាជការ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

-រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។ ចំពោះកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានការទទួលស្គាល់បន្ថែមពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា ( សេចក្តីសម្រេចលេខ ០២ / ០៤ គ.ទ.ក.ស.ស.រ ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៤ ស្តីពីលក្ខខណ្ឌសំរាប់ចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សា ) ។

-ផ្តល់ និងរួមផ្តល់ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលដទៃទៀត នូវសញ្ញាប័ត្រកំរិតជាតិ ។

-សិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារជាភាសាខ្មែរ និងបរទេសសំរាប់ជាមូលដ្ឋាន នៃការស្រាវជ្រាវ ការរៀន ការបង្រៀន និងសំរាប់ផ្សព្វផ្សាយទូទៅ ។

-រៀបចំ និងដំណើរការការងារ ជ្រើសរើសនិស្សិតឱ្យចូលរៀន ការប្រឡងចេញ និងការវាយតម្លៃលទ្ធផលសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព ។

-កសាងផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ **ស.ភ.ន.វ.ស** ។

-គ្រប់គ្រងមន្ត្រីរាជការ កម្មករ សាស្ត្រាចារ្យ និស្សិត និងទ្រព្យសម្បត្តិរបស់ **ស.ភ.ន.វ.ស** ។

-ធ្វើសហប្រតិបត្តិការ ជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការសិក្សា ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសទំនើប ។

**ប្រការ ៣** : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានរចនាសម្ព័ន្ធដូចតទៅ ÷

-មានសាកលវិទ្យាធិការមួយរូប ជាអ្នកដឹកនាំនិងគ្រប់គ្រង ព្រមទាំងសាកលវិទ្យាធិការរងចំនួនមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

-មានមហាវិទ្យាល័យចំនួន ៤ និងថ្នាក់ក្រោយបរិញ្ញាបត្រមួយដែលមានកំរិតស្មើមហាវិទ្យាល័យ ÷

១-មហាវិទ្យាល័យ នីតិសាស្ត្រ មានដេប៉ាតឺម៉ង់ពីរគឺ : ដេប៉ាតឺម៉ង់ នីតិសាធារណៈ និងដេប៉ាតឺម៉ង់នីតិឯកជន

២-មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និង គ្រប់គ្រង មានដេប៉ាតឺម៉ង់ពីរគឺ : ដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនិងដេប៉ាតឺម៉ង់គណនេយ្យ និង គ្រប់គ្រង

៣-មហាវិទ្យាល័យ សេដ្ឋកិច្ចពតិមានវិទ្យា

៤-មហាវិទ្យាល័យរដ្ឋបាលសាធារណៈ

៥-ថ្នាក់ក្រោយបរិញ្ញាប័ត្រ

-មានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមួយដែលមានឋានៈស្មើការិយាល័យ

-មានលេខាធិការដ្ឋានមួយឋានៈស្មើការិយាល័យជាជំនួយការអោយសាកលវិទ្យាធិការ និងការិយាល័យចំនួន៥គឺៈ

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យសិក្សា

៣-ការិយាល័យស្រាវជ្រាវ

៤ការិយាល័យទំនាក់ទំនងអន្តរជាតិ

៥-ការិយាល័យគណនេយ្យ

**ប្រការ ៤** : អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ . ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៤

**រដ្ឋមន្ត្រីស្តីទី**

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

"ដើម្បីជ្រាបជាពត៌មាន"

-ដូចក្នុងប្រកាស ៤

-កាលប្បវត្តិ-ឯកសារៈនា.បុគ្គលិក

{ FILENAME }